**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ សរសេរជាអក្សរកាត់ថា "**គ.ប.ក.**" ដើម្បីជាយន្តការក្នុងការប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ប.ក.

**មាត្រា២ ..**

សមាសភាពរបស់ **គ.ប.ក.** ដែលបង្កើតឡើងដោយសេចក្ដីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល ត្រូវបានកែសម្រួលដូចខាងក្រោម៖

| | |
|---|---|
| ១-**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៦-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៧-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ៩-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១២-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១៣-រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ១៤-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១៥-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៦-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១៧-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៨-រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៩-ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២០-ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល | សមាជិក |
| ២១-រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | សមាជិក |
| ២២-រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ | សមាជិក |
| ២៣-រដ្ឋលេខាធិការប្រចាំការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៤-រដ្ឋលេខាធិការប្រចាំការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៥-រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៦-រដ្ឋលេខាធិការក្រសួងសុខាភិបាល មួយចំនួន | សមាជិក |
| ២៧-អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២៨-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៩-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ៣០-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៣១-អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ **គ.ប.គ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ប.គ.** បំពេញការងាររបស់ខ្លួនក្រោមការដឹកនាំ និងបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី និងជាប្រធាន **គ.ប.គ.**។

**គ.ប.គ.** អាចផ្តល់ការណែនាំដល់ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានារបស់រាជរដ្ឋាភិបាល ឱ្យអនុវត្តផែនការបន្ទាន់ទាំងឡាយតាមការចាំបាច់ដើម្បីចូលរួមក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

ក្នុងករណីចាំបាច់ **គ.ប.គ.** អាចអញ្ជើញរដ្ឋមន្ត្រី រដ្ឋលេខាធិការ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ។

**មាត្រា៣ ..**

**គ.ប.គ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- កំណត់គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សំដៅកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ដល់វិស័យសុខភាពសាធារណៈ និងធានាដល់និរន្តរភាពនៃកិច្ចដំណើរការ និងជំរុញការស្ទុះងើបឡើងនៃវិស័យសង្គម-សេដ្ឋកិច្ចតាម "**គន្លងប្រក្រតីភាពថ្មី**"
- ដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងការប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩
- គ្រប់គ្រងផលប៉ះពាល់លើទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ទាំងកម្រិតជាតិ និងអន្តរជាតិ និង
- ដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការជាអន្តរវិស័យ អន្តរស្ថាប័ន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាមួយដៃគូដែលមានការពាក់ព័ន្ធ។

**មាត្រា៤ ..**

**គ.ប.គ.** មានគណៈប្រចាំការមួយ ជាសេនាធិការប្រចាំការ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥-រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៩-រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០-រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ | សមាជិក |
| ១២-រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-រដ្ឋលេខាធិការប្រចាំការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤-រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

| | |
|---|---|
| ១៥-រដ្ឋលេខាធិការក្រសួងសុខាភិបាល មួយចំនួន | សមាជិក |
| ១៦-អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៧-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៨-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៩-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

គណៈប្រចាំការនៃ **គ.ប.ក.** អាចមានសមាសភាពចូលរួមផ្សេងទៀត តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់គណៈប្រចាំការនៃ **គ.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ប្រធានគណៈប្រចាំការនៃ **គ.ប.ក.** អាចអញ្ជើញរដ្ឋមន្ត្រី រដ្ឋលេខាធិការ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ តាមការចាំបាច់។

គណៈប្រចាំការនៃ **គ.ប.ក.** មានភារកិច្ចដូចតទៅ៖

- ដឹកនាំការអនុវត្តបទបញ្ជា និងការណែនាំនានារបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ដឹកនាំ និងសម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ប.ក.** និងយន្តការនានាដែលចំណុះឱ្យ **គ.ប.ក.** ព្រមទាំងយន្តការពាក់ព័ន្ធផ្សេងទៀត លើការងារប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ដឹកនាំ និងសម្របសម្រួលការរៀបចំ "**ផែនការយុទ្ធសាស្ត្រ**" ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងបង្កើនភាពម្ចាស់ការសំដៅធានាដល់និរន្តរភាពនៃកិច្ចដំណើរការ និងជំរុញការស្ទុះងើបឡើងនៃវិស័យសង្គម-សេដ្ឋកិច្ច តាម "**គន្លងប្រក្រតីភាពថ្មី**"
- ណែនាំ និងសម្របសម្រួលការអនុវត្តវិធានការប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់គណៈកម្មការនានាចំណុះឱ្យ **គ.ប.ក.** និងយន្តការពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលសំដៅពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្ត
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល អំពីសភាពការណ៍វិវត្តនៃជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាល។

គណៈប្រចាំការនៃ **គ.ប.ក.** ប្រើប្រាស់គណៈប្រតិបត្តិរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជាលេខាធិការដ្ឋានរបស់ខ្លួន។

## ជំពូកទី៣
## យន្តការចំណុះឱ្យ គ.ប.ក.

**មាត្រា៥ .-**

**គ.ប.ក.** មានគណៈកម្មការក្រោមឱវាទ ដូចខាងក្រោម៖

- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សរសេរជាអក្សរកាត់ថា "**គ.អ.ក.**"
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស សរសេរជាអក្សរកាត់ថា "**គ.ទ.ក-១៩**"
- គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ សរសេរជាអក្សរកាត់ថា "**គ.ល.ទ.**"

- គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត សរសេរជាអក្សរកាត់ថា "**គ.រ.ខ.**"។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតគណៈកម្មការ ឬយន្តការផ្សេងទៀត ដោយសេចក្តីសម្រេចតាមសំណើរបស់គណៈប្រចាំការនៃ **គ.ម.គ.** ដើម្បីបម្រើឱ្យការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**មាត្រា៦ ..**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥-រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៦-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៧-រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៨-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៩-រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ១០-អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ១១-មេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| ១២-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៤-រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥-រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៦-រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៧-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៨-រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩-រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២០-រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ២១-រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ២២-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៣-អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក។ |

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អាចមានសមាសភាពចូលរួមផ្សេងទៀត ដោយយោងតាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧ ..**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការផ្នែកបច្ចេកទេស និងប្រតិបត្តិការរបស់ **គ.ជ.គ.**
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- រៀបចំផែនការឆ្លើយតបនឹងជំងឺកូវីដ-១៩ ទៅតាមការវិវត្តនៃការរីករាលដាលនៃជំងឺកូវីដ-១៩
- រៀបចំផែនការទប់ស្កាត់ការនាំចូល និងការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី
- រៀបចំផែនការធនធានមនុស្ស ធនធានសម្ភារ និងធនធានថវិកា ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា
- គ្រប់គ្រង និងវាយតម្លៃសភាពការវិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ដើម្បីដាក់ចេញវិធានការឆ្លើយតបឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា
- គ្រប់គ្រងសេវាមន្ទីរពិសោធន៍ ដោយមានការពិគ្រោះយោបល់ពីគ្រប់ដៃគូពាក់ព័ន្ធ
- ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្រប់ដៃគូពាក់ព័ន្ធលើកិច្ចការសហប្រតិបត្តិការដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- គ្រប់គ្រងផ្នែកសេវាព្យាបាល និងថែទាំដោយបង្កើតផែនការឆ្លើយតបបន្ទាន់សម្រាប់មន្ទីរពេទ្យ
- គ្រប់គ្រងការបង្ការ និងត្រួតពិនិត្យការចម្លងមេរោគកូវីដ-១៩ ដោយអនុវត្តវិធានការប្រកបដោយសុវត្ថិភាព
- ធានាការផ្គត់ផ្គង់ធនធានមនុស្ស ធនធានបរិក្ខារ ឱសថ និងធនធានថវិកា
- ធ្វើបច្ចុប្បន្នភាពឆ្លើយតបបន្ទាន់សម្រាប់ច្រក-ចេញចូលអាកាសយានដ្ឋាន កំពង់ផែ និងច្រកផ្លូវគោក
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងទិន្នន័យ និងផ្តល់ព័ត៌មានអំពីអ្នកដែលមានផ្ទុកមេរោគកូវីដ-១៩, អ្នកធ្វើចត្តាឡីស័ក និងបុគ្គលដែលមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ និងអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩, ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងអ្នកជំងឺ, ការគ្រប់គ្រង និងកិច្ចការវ៉ាក់សាំង ព្រមទាំងការងារពាក់ព័ន្ធផ្សេងទៀត
- ណែនាំការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ណែនាំការអនុវត្តវិធានការឱ្យបានត្រឹមត្រូវក្នុងការឆ្លើយតបទៅនឹងឧប្បត្តិហេតុ ឬការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- ពង្រឹង និងសម្របសម្រួលការអនុវត្តច្បាប់ អនុក្រឹត្យ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ នៅទូទាំងប្រទេស
- អនុវត្តសកម្មភាពតាមផែនការដែលបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល
- ដឹកនាំសម្របសម្រួលលើការអនុវត្តការងាររបស់អនុគណៈកម្មការ និងយន្តការនានាចំណុះគណៈកម្មការអន្តរក្រសួង ព្រមទាំងជាមួយយន្តការពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ដឹកនាំសម្របសម្រួលផ្នែកបច្ចេកទេស និងប្រតិបត្តិការលើការអនុវត្តការងាររបស់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- លើកទិសដៅប្រតិបត្តិ តាមស្ថានភាពជាក់ស្តែងនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- រាយការណ៍ជាប្រចាំជូន **គ.ជ.គ.** អំពីសភាពការណ៍វិវត្តនៃជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ **គ.ជ.គ.**។

**មាត្រា៨ ..**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានគណៈប្រតិបត្តិមួយជាយន្តការដឹកនាំ និង

សម្របសម្រួលការងារប្រចាំថ្ងៃទាក់ទងនឹងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងសម្របសម្រួលការអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត។

គណៈប្រតិបត្តិរបស់ **គ.អ.ក.** អាចមានក្រុមការងារមួយចំនួនតាមការចាំបាច់ ដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់ **គ.អ.ក.** ដើម្បីគាំទ្រដល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន។

**មាត្រា៩ ..**

គណៈប្រតិបត្តិនៃ **គ.អ.ក.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦-រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ប្រធានអនុគណៈកម្មការនីមួយៗ | សមាជិក។ |

គណៈប្រតិបត្តិនៃ **គ.អ.ក.** អាចមានសមាសភាពចូលរួមផ្សេងទៀត តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈប្រតិបត្តិនៃ **គ.អ.ក.** មានភារកិច្ចដូចខាងក្រោម៖

- ជាយន្តការប្រចាំបញ្ជា និងសម្របសម្រួលផ្នែកបច្ចេកទេស និងប្រតិបត្តិការលើការងារប្រចាំថ្ងៃក្នុងការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេស
- សម្របសម្រួលការអនុវត្តការងាររបស់អនុគណៈកម្មការចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩, គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត និងអង្គភាពប្រតិបត្តិការផ្សេងទៀត ដើម្បីធានាប្រសិទ្ធភាព និងភាពរលូននៃការអនុវត្តវិធានការក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បូកសរុបការងារ និងលើកសំណើផ្សេងៗជូន **គ.ម.ក.** ពិនិត្យ និងសម្រេច។

គណៈប្រតិបត្តិនៃ **គ.អ.ក.** មានលេខាធិការដ្ឋានមួយ ដែលស្ថិតក្រោមការដឹកនាំរបស់អនុប្រធានអចិន្ត្រៃយ៍ សម្រាប់ជួយលើការងាររដ្ឋបាលទូទៅ។ សមាសភាពរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.អ.ក.**។

**មាត្រា១០ ..**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានអនុគណៈកម្មការមួយចំនួន និងអាចមានយន្តការផ្សេងទៀត ជាសេនាធិការផ្នែកបច្ចេកទេស និងប្រតិបត្តិការ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងយន្តការនានាចំណុះឱ្យគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ម.ក.** លើកលែងតែ

យន្តការក្រោមគណៈប្រតិបត្តិនៃ **គ.អ.ក.** ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.អ.ក.** ដូចមានចែងក្នុងមាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា១១ ..**

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត មានភារកិច្ចដឹកនាំកិច្ចប្រតិបត្តិការក្នុងការប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរាជធានី-ខេត្តនីមួយៗ។

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងមានអភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្តមួយរូប ជាអនុប្រធានប្រចាំការ ព្រមទាំងមានប្រធានមន្ទីរសុខាភិបាល ស្នងការនគរបាល មេបញ្ជាការកងរាជអាវុធហត្ថ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរជំនាញរាជធានី-ខេត្ត ជាសមាជិក។

សមាសភាពជាក់ស្តែងនៃគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវកំណត់ដោយដីការបស់រដ្ឋបាលរាជធានី-ខេត្ត។

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត អាចមានក្រុមការងារ ឬយន្តការមួយចំនួនតាមការចាំបាច់ ដែលត្រូវបង្កើតឡើងដោយដីកាសម្រេចរបស់រដ្ឋបាលរាជធានី-ខេត្ត ដើម្បីបម្រើដល់ការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវអនុវត្តការងាររបស់ខ្លួន ក្រោមការសម្របសម្រួលរបស់គណៈកម្មការអន្តរក្រសួង និង **គ.ប.ក.**។

ក្នុងករណីមានតម្រូវការចាំបាច់ និងបន្ទាន់ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត អាចស្នើសុំការគាំទ្រ និងជំនួយឧបត្ថម្ភពីគណៈកម្មការអន្តរក្រសួង និងពី **គ.ប.ក.**។

គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ប្រើកញ្ចប់ថវិការបស់រដ្ឋបាលរាជធានី-ខេត្ត និងជំនួយផ្សេងៗពីដៃគូអភិវឌ្ឍន៍ និងសប្បុរជន និងប្រើគ្រារបស់រដ្ឋបាលរាជធានី-ខេត្ត ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា១២ ..**

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស មានសមាសភាព, តួនាទី និងភារកិច្ច និងកិច្ចដំណើរការ ដូចមានកំណត់ក្នុងសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេសរបស់រាជរដ្ឋាភិបាល។

**មាត្រា១៣ ..**

ក្រុមការងារអន្តរក្រសួងទទួលបន្ទុកការងារចរចា និងការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១០៩ សសរ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុកការងារចរចា និងការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវបានកែសម្រួលទៅជាគណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។ គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មានសមាសភាព, តួនាទីនិងភារកិច្ច ព្រមទាំងកិច្ចដំណើរការ ដូចបានកំណត់ក្នុងសេចក្តីសម្រេចលេខ ១០៩ សសរ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល។

**មាត្រា១៤ .-**

យន្តការស្ថាប័ន និងមុខងារដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តរហូតដល់ការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់ជាស្ថាពរ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា១៥ .-**

រាល់យន្តការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានយន្តការ និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ